**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣ ❖ ៤៤

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៦៩៧ អយក.ប្រក**

# ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា **ហ៊ុន សែន បណ្ឌិត**

ជាសាលាបឋមសិក្សា ពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត ស្នើសុំលេខ ៣៤ អយក តបម ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ២០០២ របស់ប្រធានមន្ទីរ អប់រំយុវជន និង កីឡា ខេត្ត **តាកែវ**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## ស ំ រេ ច

**<u>ប្រការ១</u>** : បើកសាលាបឋមសិក្សា **ហ៊ុន សែន បណ្ឌិត** ដែលមានទីតាំងស្ថិតនៅភូមិ **ស្រីប្រសើរ** ឃុំ **ស្លា** ស្រុក **សំរោង** ខេត្ត **តាកែវ** ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**<u>ប្រការ២</u>** : សាលាបឋមសិក្សា **ហ៊ុន សែន បណ្ឌិត** ត្រូវដឹកនាំដោយ នាយក១រូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**<u>ប្រការ៣</u>** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**<u>ប្រការ៤</u>** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត**តាកែវ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **សំរោង** នាយកសាលាបឋមសិក្សា **ហ៊ុន សែន បណ្ឌិត** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០០៣

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **តាកែវ**

" **<u>ដើម្បីជូនជ្រាបជាពត៌មាន</u>** "

-ដូចប្រការ ៤

-កាលប្បវត្តិ-ឯកសារ នា.បស